# ទស្សនវិស័យ បេសកកម្ម និងគុណតំលៃអង្គការ

ដោយ ឡេងឆាយ

## ទស្សនវិស័យ Vision

ទស្សនៈវិស័យជារូបភាពគោលមួយនៃជោគជ័យដែលនឹងកើតឡើង ក្នុងន័យរួមចំណែកដល់សង្គម។ វាឆ្លើយនឹងសំនួរថាតើ "ជោគជ័យនឹងមានរាងដូចម្តេច"។ វាជាការស្វែងរកនូវរូបភាពនៃជោគជ័យមួយ ដែលជំរុញទឹកចិត្តអោយបុគ្គលិកខំធ្វើការជាមួយគ្នា។ទស្សនវិស័យមួយស្ថិតនៅក្រៅការត្រួតត្រារបស់អង្គការមួយ មានន័យថា អង្គការច្រើនរួមចំណែកទៅសំរេចទស្សនវិស័យមួយ។

### ឧទាហរណ៍:

- សង្គមមួយដែលបុរស និងស្ត្រីមានសិទ្ធិ និងឪកាសស្មើរគ្នា។
- ប្រជាពលរដ្ឋជនបទកម្ពុជារស់នៅក្នុងសន្តិភាព និងភាពរុងរឿង។
- សង្គមមួយដែលប្រជាពលរដ្ឋរស់នៅសុខសាន្ត ដោយស្មើរភាពគ្នាចំពោះមុខច្បាប់។

## បេសកកម្ម Mission

បេសកកម្មឆ្លើយនឹងសំនួរថា តើហេតុអ្វីបានជាមានអង្គការ(គោលបំណង), អង្គការនោះធ្វើការងារផ្នែកអ្វី (សកម្មភាពចំបងៗ/វិធីសាស្ត្រ) ហើយអង្គការនោះបំរើអ្នកណា (ក្រុមគោលដៅ)។ ឃ្លាបេសកកម្មមួយមានពីរផ្នែកៈ

- ឃ្លាគោលបំណង: បញ្ជាក់ពីអ្វីដែលអង្គការអ្នកចង់សំរេច។ ឧ.លើកកំពស់សិទ្ធិស្ត្រី លើកកំពស់កំរិតជីវភាព លើកកំពស់យុត្តិធម៌។ល។
- ឃ្លាសកម្មភាព ឬអាជីវកម្ម: សកម្មភាព ឬកម្មវិធីដែលអង្គការអ្នកជ្រើសរើសដើម្បីសំរេចគោលបំណង។ ឧ.ផ្តល់សេវាអប់រំ និងប្រឹក្សាយោបល់ ផ្តល់សេវាហិរញ្ញវត្ថុ ធ្វើការតស៊ូមតិដើម្បីសិទ្ធិ។ល។

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

ឧទាហរណ៍៖

- ផ្តល់សេវាអប់រំ និងប្រឹក្សាយោបល់ ដល់ស្ត្រីរងគ្រោះនៅប្រទេសកម្ពុជា ដើម្បីលើកកំពស់ សិទ្ធិនិងឪកាសស្ត្រី។
- លើកកំពស់កំរិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋជនបទ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុ ដែលឆ្លើយតបនឹងតំរូវការអាជីវកម្មខ្នាតតូចរបស់គេ។
- ធ្វើការតស៊ូមតិ ដើម្បីសិទ្ធិអ្នកក្រ និងអ្នកងាយរងគ្រោះ ដើម្បីលើកកំពស់យុត្តិធម៌ក្នុងសង្គម។

## គុណតំលៃ Values

គុណតំលៃជាជំនឿដែលណែនាំ ឬជំរុញដល់អាកប្បកិរិយាឬសកម្មភាព។ គុណតំលៃអង្គការជាជំនឿដែលបុគ្គលិកមានរួមគ្នា ហើយព្យាយាមដាក់បញ្ចូលទៅក្នុងការអនុវត្តជាក់ស្តែង។ គុណតំលៃមានសារៈសំខាន់ណាស់ចំពោះអង្គការ ព្រោះវាជួយណែនាំអាកប្បកិរិយាបុគ្គលិកក្នុងការបំពេញការងាររបស់គេ ជួយបង្កើនប្រសិទ្ធភាពអង្គការ និងសំរេចបេសកកម្ម និងទស្សនៈវិស័យ។

*ឧ.ពាក្យគុណតំលៃ:* ការងារក្រុម ការគោរពចំរុះភាព ភាពស្មោះត្រង់ ភាពជាអាជីព សុច្ចរិតភាព លទ្ធផលជាចំបង សមភាពយេនឌ័រ ការអភិវឌ្ឍបុគ្គលភាព ភាពច្នៃប្រឌិត ការរៀនសូត្រ។ល។

*ឧ.ឃ្លាគុណតំលៃ:*

- យើងជឿថាបរិភោគបន្លែមានសុខភាពល្អជាងបរិភោគសាច់ជ្រូក។
- យើងជឿថាការរៀនសូត្រជាបនបន្ទាប់នឹងលើកកំពស់ប្រសិទ្ធភាពអង្គការ។
- យើងជឿថាស្ត្រីអាចរួមចំណែកយ៉ាងលេចធ្លោរក្នុងការផ្លាស់ប្តូរសង្គម។

*សំគាល់:* យើងត្រូវមានដំណើរការមួយដែលមានការចូលរួមយ៉ាងពេញលេញ និងការសំរបសំរួលសមស្រប ដើម្បីបង្កើតទស្សនៈវិស័យ បេសកកម្ម និងគុណតំលៃរួម ដែលល្អ។

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.